# សេចក្តីថ្លែងការណ៍រួមរបស់អង្គការសង្គមស៊ីវិល

**សេចក្តីថ្លែងការណ៍រួមរបស់អង្គការសង្គមស៊ីវិលក្នុងឱកាសទិវាសិទ្ធិមនុស្សអន្តរជាតិ ឆ្នាំ២០២៥**

**" សារៈសំខាន់នៃការគោរពជាប្រចាំថ្ងៃនូវតម្លៃសិទ្ធិមនុស្ស លំហសេរីភាពប្រជាពលរដ្ឋ និងសិទ្ធិអ្នកការពារសិទ្ធិមនុស្ស។"**

**ស្របតាមមូលបទអន្តរជាតិ៖ "ភាពចាំបាច់ប្រចាំថ្ងៃនៃសិទ្ធិមនុស្ស" (Human Rights, Our Every Day Essentials)**

ភ្នំពេញ, ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៥៖ ក្នុងឱកាសទិវាសិទ្ធិមនុស្សអន្តរជាតិ ឆ្នាំ២០២៥ នេះ អង្គការសង្គមស៊ីវិលដែលគាំទ្រដូចខាងក្រោមដូចខាងក្រោមនៅកម្ពុជា សូមបញ្ជាក់ថ្មីនូវសារៈសំខាន់នៃការគោរពជាប្រចាំថ្ងៃនូវតម្លៃសិទ្ធិមនុស្ស ដែលជាសារសំខាន់សម្រាប់សេចក្តីថ្លៃថ្នូរ សុខមាលភាព យុត្តិធម៌ សមភាព សន្តិភាព និងការការពារប្រជាពលរដ្ឋទាំងអស់ក្រោមច្បាប់ ហើយសិទ្ធិមនុស្សជាទីសដៅរួមនៃការអភិវឌ្ឍន៍របស់ប្រទេស។

ក្នុងបរិបទដែលសម្ពាធសង្គម សេដ្ឋកិច្ច និងនយោបាយកំពុងជះឥទ្ធិពលកាន់តែខ្លាំងឡើងទៅលើសេរីភាពជាមូលដ្ឋាន យើងសូមគូសបញ្ជាក់ពីតម្រូវការបន្ទាន់ក្នុងការការពារសិទ្ធិមនុស្សជាសកល និងលំហពលរដ្ឋដែលតម្រូវឲ្យបុគ្គល និងសហគមន៍អាចចូលរួមដោយសេរីក្នុងការកសាងសង្គមរបស់ពួកគេ ។

ឆ្នាំនេះ សង្គមស៊ីវិលកម្ពុជាប្រារព្ធទិវានេះក្រោមមូលបទ " សារៈសំខាន់នៃការគោរពជាប្រចាំថ្ងៃនូវតម្លៃសិទ្ធិមនុស្ស លំហសេរីភាពប្រជាពលរដ្ឋ និងសិទ្ធិអ្នកការពារសិទ្ធិមនុស្ស" ដែលតម្រូវតាមប្រធានបទសកល " **ភាពចាំបាច់ប្រចាំថ្ងៃនៃសិទ្ធិមនុស្ស**" ។ ប្រធានបទទាំងពីរនេះបានគូសបញ្ជាក់ថា សិទ្ធិមនុស្សមិនមែនជាឧត្តមគតិអរូបីទេ តែជាតម្រូវការចាំបាច់ប្រចាំថ្ងៃ ដែលអនុញ្ញាតឲ្យបុគ្គល គ្រួសារ និងសង្គមរីកចម្រើន ។

## លំហរបស់សង្គមស៊ីវិលនៅកម្ពុជាមានការរួមតូច

យើងសូមសម្តែងនូវការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការបន្តធ្លាក់ចុះនៃលំហរបស់សង្គមស៊ីវិលនៅកម្ពុជា។ លំហសាធារណៈសម្រាប់ការចូលរួម ការបញ្ចេញមតិ និងការប្រមូលផ្តុំមានការរួមតូចជាលំដាប់ ដោយបានកាត់បន្ថយសមត្ថភាពរបស់សាធារណជនក្នុងការសម្តែងការព្រួយបារម្ភ ក្នុងការទាមទារការទទួលខុសត្រូវពីស្ថាប័នរដ្ឋ និងក្នុងការចូលរួមកិច្ចសន្ទនា ។

ការព្រួយបារម្ភជាចម្បងរួមមាន៖

- ការកើនឡើងនៃការប្រើប្រាស់បទប្បញ្ញត្តិព្រហ្មទណ្ឌ ជាពិសេស មាត្រា ៤៩៥ (បទញុះញង់) និងបរិហារកេរ្តិ៍ ដែលបង្កើតនូវការភ័យខ្លាចក្នុងការចូលរួមជាសាធារណៈនៅក្នុងជីវិតសង្គម និងនយោបាយ ។
- ការរឹតត្បិតលើការប្រមូលផ្តុំដោយសន្តិវិធី រួមទាំងការតាមដានយ៉ាងជិតដល់ វត្តមានមន្ត្រីជាន់ខ្ពស់ និងការដាក់ពង្រាយកម្លាំងប្រដាប់អាវុធយ៉ាងគំហុកនៅជុំវិញការប្រជុំស្របច្បាប់ និងជាប្រពៃណី ដែលបង្កឲ្យមានបរិយាកាសគំរាមកំហែង និងការភ័យខ្លាចសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋ និងសង្គមស៊ីវិល ។
- ការរឹតបន្តឹងផ្នែករដ្ឋបាល និងការត្រួតពិនិត្យលើអង្គការសង្គមស៊ីវិល ។
- ការគាបសង្កត់លើប្រព័ន្ធឌីជីថលដែលសំដៅទៅលើអ្នករិះគន់តាមអនឡាញ សកម្មជន និងអ្នកសារព័ត៌មាន ។

សម្ពាធទាំងនេះបានធ្វើឲ្យប៉ះពាល់ដល់អភិបាលកិច្ចប្រជាធិបតេយ្យ គណនេយ្យភាព និងការចូលរួមប្រកបដោយបរិយាបន្នដែលជាមូលដ្ឋានគ្រឹះនៃសង្គមប្រកបដោយសន្តិភាព ។

## អ្នកការពារសិទ្ធិមនុស្ស និងក្រុមងាយរងគ្រោះ

អ្នកការពារសិទ្ធិមនុស្ស រួមមានតំណាងសហគមន៍ អ្នកការពារបរិស្ថាន មេដឹកនាំសហជីព អ្នកសារព័ត៌មាន និងសកម្មជនអនឡាញ បន្តប្រឈមនឹងការចាប់ខ្លួន ការឃុំខ្លួនបណ្ដោះអាសន្ន យូរអង្វែង ការយាយីផ្លូវច្បាប់ និងការគំរាមកំហែងចំពោះកិច្ចការដោយសន្តិវិធីរបស់ពួកគេ ។

ទោះបីជាមានតួនាទីសំខាន់ក៏ដោយ ក៏កម្ពុជានៅតែខ្វះយន្តការការពារជាតិ ដែលស្របតាម សេចក្តី-ប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីអ្នកការពារសិទ្ធិមនុស្ស ជាពិសេសសម្រាប់សហគមន៍ដែលរងផលប៉ះពាល់ដោយការរំលោភដីធ្លី អ្នកការពារបរិស្ថាន និងជនជាតិដើមភាគតិច ។

ក្រុមទាំងនេះទាមទារនូវបរិយាកាសដែលប្រកបដោយបរិយាបន្ន សមភាព សុវត្ថិភាព និងបើកចំហរ ដែលសំឡេងរបស់ពួកគេអាចត្រូវបានឮដោយគ្មានការភ័យខ្លាច ។

## ស្ថានភាពសិទ្ធិមនុស្សៈ ទិន្នន័យថ្មីៗ (ឆ្នាំ២០២៥)

- យោងតាមអង្គការលីកាដូ (LICADHO) ប្រជាពលរដ្ឋជិត ១០០នាក់ត្រូវបានចាប់ខ្លួន ពាក់ព័ន្ធនឹងការប្រើប្រាស់សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិរបស់ពួកគេ ។
- របាយការណ៍របស់ CamboJA បង្ហាញថា ចាប់ពី ខែកក្កដា ដល់ ខែកញ្ញា ឆ្នាំ២០២៥ កម្ពុជាបានកត់ត្រានូវ ការរំលោភសិទ្ធិមនុស្សចំនួន ២៣ ករណី លើអ្នកសារព័ត៌មាន និងស្ថាប័នសារព័ត៌មាន ដែលជាការកើនឡើងគួរឲ្យព្រួយបារម្ភដល់ ១៣០% បើប្រៀបធៀបទៅនឹងត្រីមាសមុន ។
- ចាប់ពី ខែមករា ដល់ ខែកញ្ញា ឆ្នាំ២០២៥ ករណីរំលោភបំពានសរុបចំនួន ៤៧ ករណី លើអ្នកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយត្រូវបានកត់ត្រា រួមទាំង ការយាយីផ្លូវច្បាប់ចំនួន ៣៧ ករណី (៧៩%) ការវាយប្រហារផ្លូវកាយចំនួន ៥ ករណី និងការដកហូតអាជ្ញាប័ណ្ណចំនួន ៥ ករណី ។
- ៨៧% នៃការរំលោភបំពានទាំងនេះ ត្រូវបានប្រព្រឹត្តដោយតួអង្គរដ្ឋនៅថ្នាក់មូលដ្ឋាន ខេត្ត និងថ្នាក់ជាតិ ។

ទិន្នន័យថ្មីៗទាំងនេះបានគូសបញ្ជាក់ពីភាពបន្ទាន់នៃការការលំហរបស់សង្គមស៊ីវិល និងសេរីភាពជាមូលដ្ឋាន ហើយឆ្លុះបញ្ចាំងពីលំនាំទូលំទូលាយនៃការរួមតូចនៃសេរីភាព និងហានិភ័យកាន់តែរីកលូតលាស់សម្រាប់អ្នកដែលកំពុងប្រើប្រាស់សិទ្ធិជាមូលដ្ឋានរបស់ពួកគេ ។

## តួនាទីរបស់យុវជនក្នុងការលើកកម្ពស់សិទ្ធិមនុស្ស

យើងសូមគូសបញ្ជាក់ពីតួនាទីដ៏សំខាន់របស់យុវជនក្នុងនាមជាអ្នកដឹកនាំ អ្នកទំនាក់ទំនង អ្នកការពារ និងអ្នកបង្កើតការផ្លាស់ប្តូរ ។ យុវជនបាននាំមកនូវថាមពល ភាពច្នៃប្រឌិត និងក្តីសង្ឃឹមដល់កិច្ចការសិទ្ធិមនុស្ស ហើយការចូលរួមរបស់ពួកគេគឺចាំបាច់សម្រាប់ការកសាងសង្គមសមធម៌ដែលមានមូលដ្ឋានលើយុត្តិធម៌ តម្លាភាព គណនេយ្យភាព និងមិនមានការរើសអើង ។ ការធានានូវបរិយាកាសសុវត្ថិភាព បើកចំហ និងអំណោយផលសម្រាប់យុវជនគឺជាកត្តាសំខាន់សម្រាប់អនាគតប្រជាធិបតេយ្យរបស់កម្ពុជា ។

ការព្រួយបារម្ភរបស់យើងនៅតែស្របតាមសេចក្តីសន្និដ្ឋាន និងអនុសាសន៍នៃការត្រួតពិនិត្យជាសកលតាមកាលកំណត់ (UPR) – វដ្តទី៤ ជាពិសេសអនុសាសន៍/សេចក្តីសន្និដ្ឋានដែលរាជរដ្ឋាភិបាលកម្ពុជាបានគាំទ្រ និងកត់សម្គាល់ទាក់ទងនឹងលំហសិទ្ធិប្រជាពលរដ្ឋ និងនយោបាយ សិទ្ធិ និងសេរីភាពជាមូលដ្ឋាន និងសិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្ស (អនុសាសន៍ដែលគាំទ្រ៖ ១៣៩.១០៦, ១៣៩.១០៧) និង (អនុសាសន៍ដែលកត់សម្គាល់៖ ១៣៩.៧៦, ១៣៩.១១១, ១៣៩.៨៧ និង ១៣៩.១០២) ។

## **សំណូមពររបស់យើងចំពោះរាជរដ្ឋាភិបាលកម្ពុជា**

ក្នុងទិវាសិទ្ធិមនុស្សនេះ យើងសូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា ពិចារណាដោយយកចិត្តទុកដាក់នូវអនុសាសន៍របស់យើងដូចខាងក្រោម៖

- ដោះលែងអ្នកទោសមនសិការទាំងអស់ ដែលត្រូវបានឃុំខ្លួនសម្រាប់ការបញ្ចេញមតិ និង សកម្មភាពដោយសន្តិវិធី ដើម្បីការពារសិទ្ធិមនុស្ស ផលប្រយោជន៍ ឬតម្រូវការសាធារណៈ និងសិទ្ធិបរិស្ថាន និងសេរីភាពសារព័ត៌មាន ។
- ធានានូវនីតិវិធីច្បាប់ប្រកបដោយយុត្តិធម៌ មិនលម្អៀង និងទាន់ពេលវេលាសម្រាប់បុគ្គល ដែលប្រឈមនឹងការចោទប្រកាន់ទាក់ទងនឹងសិទ្ធិមនុស្ស ។
- បើកឡើងវិញ និងពង្រីកលំហប្រជាពលរដ្ឋ បញ្ចប់ការរឹតត្បិតដែលមិនចាំបាច់ និងដែលមិន អនុលោមតាមច្បាប់ មកលើសង្គមស៊ីវិល និងសហគមន៍ និងអនុញ្ញាតឲ្យពួកគេបំពេញតួនាទី របស់ពួកគេដោយគ្មានការភ័យខ្លាច និងគ្មានការត្រួតពិនិត្យយ៉ាងដិតដល់ពីកងកម្លាំងប្រដាប់ អាវុធច្រើនដោយមិនចាំបាច់ និងមិនមានតុល្យភាព។
- ការពារអ្នកការពារសិទ្ធិមនុស្ស បញ្ចប់ការយាយីផ្លូវតាមផ្លូវច្បាប់ដែលមិនស្របតាមបទដ្ឋាន និងការចាប់ខ្លួនអមនុស្សធម៌ លើពលរដ្ឋ រួមទាំងអ្នកការពារសិទ្ធិមនុស្សជាស្ត្រី និងអនុម័តការ ការពារជាតិដែលស្របតាមស្តង់ដារអន្តរជាតិ ។
- អនុវត្តកតិកាសញ្ញា អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស និងសម្រេចឲ្យបានពេញលេញនូវ អនុសាសន៍ UPR ដែលទាក់ទងលំហប្រជាពលរដ្ឋ និងអ្នកការពារសិទ្ធិមនុស្ស ។
- ពង្រឹងតម្លាភាព គណនេយ្យភាព និងនីតិរដ្ឋ ។
- លើកកម្ពស់កិច្ចសហការរវាងសហគមន៍ អង្គការសង្គមស៊ីវិល អ្នកអប់រំ និងស្ថាប័នរដ្ឋ ជា ពិសេសដើម្បីគាំទ្រក្រុមងាយរងគ្រោះ ។
- បញ្ឈប់ការប្រើប្រាស់បទចោទប្រកាន់ព្រហ្មទណ្ឌប្រឆាំងអ្នកសារព័ត៌មាន អ្នកសារព័ត៌មានពលរដ្ឋ និង អ្នកការពារសិទ្ធិមនុស្ស ដែលបំពេការងារពាក់ព័ន្ធនឹងសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស និង អ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម។
- បញ្ចប់និទណ្ឌភាពប្រឆាំងនឹងអ្នកសារព័ត៌មានដោយធ្វើការស៊ើបអង្កេតភ្លាមៗ ផ្តន្ទាទោស និងដោះ ស្រាយករណីហិង្សាលើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស។
- ធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌ លុបចោល ឬកែប្រែបទល្មើសញុះញង់ (មាត្រា ៤៩៤, ៤៩៥) បទបរិហាកេរ្តិ៍ជាសាធារណៈ (មាត្រា៣០៥) និង មាត្រពាក់ព័ន្ធនានា ដើម្បីឱ្យស្របតាមបទដ្ឋាន អន្តរជាតិនៃសេរីភាពនៃការបញ្ចេញមតិ។

នៅពេលដែលពិភពលោកប្រារព្ធ សិទ្ធិមនុស្សជាមូលដ្ឋានគ្រឹះប្រចាំថ្ងៃរបស់យើង យើងសូមឈរ រួបរួមគ្នាក្នុងការលើកប្តេជ្ញាជាថ្មីថា សិទ្ធិមនុស្ស លំហប្រជាពលរដ្ឋរបស់សង្គមស៊ីវិលបើកចំហ និងការ ការពារអ្នកការពារសិទ្ធិមនុស្ស គឺជាសសរស្តម្ភដ៏សំខាន់នៃប្រទេសកម្ពុជាដែលមានសន្តិភាព និង ប្រជាធិបតេយ្យ ។

យើងសូមអំពាវនាវដល់តួអង្គទាំងអស់៖ ស្ថាប័នរដ្ឋ សង្គមស៊ីវិល សហគមន៍ យុវជន និងដៃគូ អន្តរជាតិ ឲ្យរក្សាតម្លៃទាំងនេះជារៀងរាល់ថ្ងៃ និងធ្វើការរួមគ្នាឆ្ពោះទៅរកអនាគតដែលកសាងឡើង លើការគោរព សាមគ្គីភាព យុត្តិធម៌ និងការទទួលខុសត្រូវរួម ។

សេចក្តីថ្លែងការណ៍នេះគាំទ្រដោយ

1. សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA)
2. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)
3. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL)
4. សម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)
5. សហព័ន្ធសហជីពនិយោជិតវិស័យឧស្សាហកម្មកម្ពុជា (CIWF)
6. អង្គការមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC)
7. សម្ព័ន្ធសហជីពកាត់ដេរសម្លៀកបំពាក់ និងឧស្សាហកម្ម (Coalition-AI)
8. សមាគមអ្នកបើកបររថយន្តដុនជូនកម្ពុជា (CTDA)
9. សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍សេវាកម្មកម្ពុជា (CTSWF)
10. សមាគមបណ្តាញយុវជនកម្ពុជា (CYN)
11. ក្រុមពង្រឹងសិទ្ធិអំណាចយុវជនដើម្បីសមធម៌សង្គម (EYES)
12. សមាគមនកសិករដើម្បីសន្តិភាព និងអភិវឌ្ឍន៍ (FAPD)
13. សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)
14. សហព័ន្ធសហជីពឯករាជ្យ (INTUFE)
15. សមាគមខ្មែរនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (KAI)

16. សហព័ន្ធសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ( FTUWKC )
17. អង្គការភាពជាដៃគូដើម្បីបរិស្ថាន និងការអភិវឌ្ឍ ( PED )
18. មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព ( PDP-Center )
19. អង្គការអភិវឌ្ឍន៍ស្ត្រីក្រីក្រក្នុងទីក្រុង ( UPWD )